01671257

F64.1

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 17-May-21, 08:00
CMS/CFO: Sann Rada

# អនុស្សរណៈអន្តរការិយាល័យ

**ជូនចំពោះ៖** ចៅក្រមប្រធាន និងចៅក្រមទាំងអស់ នៃអង្គជំនុំជម្រះតុលាការកំពូល

កាលបរិច្ឆេទ៖ ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១

**ពី៖** ឯកឧត្តម គង់ សុភី ប្រធានផ្នែកគ្រប់គ្រងតុលាការ

**កម្មវត្ថុ៖** ការជូនដំណឹងរបស់ផ្នែកគ្រប់គ្រងតុលាការអំពីការត្រៀមរួចរាល់សម្រាប់សវនការបណ្តឹងសាទុក្ខ ក្នុងសំណុំរឿង ០០២/២

អនុលោមតាមការជូនដំណឹងបឋមរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីបណ្តឹងសាទុក្ខ នៅក្នុងសំណុំរឿង ០០២/២[1] ផ្នែកគ្រប់គ្រងតុលាការសូមជម្រាបជូនអង្គជំនុំជម្រះឲ្យបានជ្រាបថា ផ្នែកគ្រប់គ្រងតុលាការការបានត្រៀមរួចរាល់ហើយសម្រាប់ការសម្របសម្រួល ដល់សវនាការបណ្តឹងសាទុក្ខនេះ។

១. សេវាបកប្រែ[2] និងសេវាប្រតិចារឹក[3] (រួមទាំងការត្រួតពិនិត្យ និងការចងក្រង[4]) បានត្រៀមរួចរាល់សម្រាប់បំពេញការងារ ដោយត្រូវការការជូនដំណឹង តែត្រឹម ៦ សប្តាហ៍ប៉ុណ្ណោះ[5]។

២. ការកែសម្រួលជារូបវ័ន្តទៅលើសាលសវនាការ អ.វ.ត.ក បានបញ្ចប់រួចរាល់នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២១ អនុលោមទៅតាមអនុសាសន៍របស់មន្ត្រីទំនាក់ទំនងវេជ្ជសាស្ត្រសម្រាប់កូវីដ១៩ នៃការិយាល័យអ្នកសម្របសម្រួលរបស់អង្គការសហប្រជាជាតិ ប្រចាំប្រទេសកម្ពុជា និងអ្នកសម្របសម្រួលការពារ

---

[1] ឯកសារ F58. ផ្នែកគ្រប់គ្រងតុលាការ បានកត់សម្គាល់ អំពីការផ្អាកសវនការ ទៅកាលបរិច្ឆេទនាពេខាងមុខ (ឯកសារ F62) ។

[2] ភាសាខ្មែរ៖ ផ្ទាល់ ភាសាអង់គ្លេស និងបារាំង (ពីចម្ងាយ): EOI/ITU/2019/7។

[3] ភាសាខ្មែរ៖ ផ្ទាល់ ភាសាអង់គ្លេស និងបារាំង (ពីចម្ងាយ): UNK/PU/CON/18/08។

[4] ភាសាខ្មែរ៖ ផ្ទាល់ ភាសាអង់គ្លេស និងបារាំង (ពីចម្ងាយ): EOI/TU/2019/15។

[5] សេវាកម្មបែបកិច្ចសន្យា ដូចជាប្រតិចារឹក និងការបកប្រែ គឺអាស្រ័យលើលទ្ធភាពទំនេរ របស់អ្នកផ្តល់ ឬអ្នកធ្វើការក្រៅក្របខណ្ឌ (freelancers) ដែលផ្តល់សេវាជូនអតិថិជន នៅទូទាំងពិភពលោក។ ហេតុដូច្នេះ គួរតែមានការជូនដំណឹងយ៉ាងតិចបំផុត ៦សប្តាហ៍មុន ដើម្បីធានាពីលទ្ធភាពទំនេររបស់ពួកគេ។

F Chl

ផ្លូវមុខនៃអង្គការអន្តរជាតិទេសន្តរប្រវេសន៍[6]។ រូបគំនូរបំព្រួញ និងរូបថតនៃការកែសម្រួលជារូបវ័ន្ត បានដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួមរួចរាល់ហើយ[7]។

៣. នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ កញ្ចប់ឧបករណ៍ឌីជីថលសម្រាប់សន្និសីទ ត្រូវបានបញ្ជាទិញ ដើម្បីបំពេញតាមតម្រូវការរបស់អ្នកចូលរួមពីចម្ងាយណាមួយ នៅក្នុងពេលសវនាការ[8]។ ផ្នែកព័ត៌មានវិទ្យាបានធ្វើការតម្លើងប្រព័ន្ធ (upgrade) ទៅលើកុំព្យូទ័រទាំងអស់ នៅក្នុងសាលសវនាការ និងបន្ទប់អ្នកបកប្រែ[9] ហើយបានទិញនិងធ្វើការបញ្ចូលគ្នានូវប្រព័ន្ធរឹង (hardware) ផ្នែកសោតទស្សន៍ និងកំពុងធ្វើការបញ្ជាទិញបណ្តាញអ៊ីនធឺណែតបម្រុង ដើម្បីឱ្យបណ្តាញទំនាក់ទំនង កាន់តែឋិតថេរជាងមុន។ បន្ទាប់ពីការបណ្តុះបណ្តាលបច្ចេកទេស នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០២១ ផ្នែកគ្រប់គ្រងតុលាការបានធ្វើតេស្តដោយជោគជ័យ នូវកញ្ចប់ឧបករណ៍ឌីជីថល សម្រាប់សន្និសីទ ពីសាលសវនាការ អ.វ.ត.ក ក្រោមស្ថានភាព "សវនាការ" ត្រាប់ ដែលរួមមានអ្នកចូលរួម និងអ្នកបកប្រែដែលនៅផ្ទាល់ និងពីចម្ងាយ ជាភាសាខ្មែរ បារាំង និងអង់គ្លេស[10]។

៤. ផ្នែកសេវាសាធារណៈបានទទួលនូវជែលលាងដៃ ទឹកអាល់កុលលាងដៃ ម៉ាស់ របាំងមុខ ទឹកបាញ់សម្លាប់មេរោគ សម្ភារៈការពារខ្លួន ស្រោមដៃ និងប្រដាប់វាស់កម្តៅកាន់ដៃ ដែលស្របទៅតាមអនុសាសន៍សុខាភិបាលដែលបានលើកឡើងពីខាងលើ[11]។ មន្ត្រីសន្តិសុខទទួលបានការណែនាំពេញលេញអំពីពិធីសារកាត់បន្ថយជាអតិបរមានូវហានិភ័យកូវីដ១៩ ហើយត្រៀមខ្លួនរួចរាល់ដើម្បីធានានូវការគោរពអនុវត្តតាម នៅក្នុងអំឡុងពេលសវនាការ។

ផ្អែកលើវិធានការខាងលើ ផ្នែកគ្រប់គ្រងតុលាការបានត្រៀមរួចរាល់ដើម្បីសម្របសម្រួលដល់សវនាការសម្រាប់អង្គជំនុំជម្រះតុលាការកំពូល ដែលជាសវនការគោរពតាមបទដ្ឋានកូវីដ១៩[12]។ ប្រសិនបើលោកប្រធាន លោក/លោកស្រីចៅក្រម មានសំណួរ ឬកង្វល់ណាមួយ សូមមេត្តាកុំស្ទាក់ស្ទើរ ក្នុងការទំនាក់ទំនងមកកាន់ខ្ញុំបាទ។

---

[6] របាយការណ៍ត្រូវបានដាក់ជាឯកសារ F61/3.4។ តួនាទីរបស់អង្គការអន្តរជាតិ ទេសន្តរប្រវេសន៍ ពាក់ព័ន្ធជាមួយកូវីដ១៩ គឺមានរៀបរាប់នៅជើងទំព័រ ៨ នៃឯកសារ F61/3។

[7] ឃ្លាំងផ្ទុកឯកសាររួម អាចរកបាននៅក្នុងប្រព័ន្ធ Zylab។

[8] សូមមើលឯកសារ F61/3 កថាខណ្ឌ ៦, PD/C0096/20។

[9] រួមមាន RAM និងប្រព័ន្ធប្រតិបត្តិការ។

[10] កំណត់ត្រាត្រូវបានដាក់ចូលទៅក្នុងឃ្លាំងផ្ទុកឯកសាររួម។

[11] សូមមើល ជើងទំព័រ ៦។

[12] ដូចជើងទំព័រខាងលើ។